ព្រឹត្តិប័ត្រសារព័ត៌មាន ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥

**ធនាគារ មេយប៊ែងនាំយកកម្មវិធីហ្វឹកហាត់កីឡាបាល់ទាត់លក្ខណៈអន្តរជាតិ Manchester United Soccer School ជាលើកដំបូងមកកាន់ប្រទេសកម្ពុជា**

*ជំរុញសក្តានុពលយុវជន និងបង្កើនការផ្តល់ជូនកាន់តែប្រសើរសម្រាប់អតិថិជន Premier តាមរយៈបទពិសោធន៍ដ៏កម្រដែលមិនអាចបំភ្លេចបាន*

**រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥** ធនាគារ មេយប៊ែង បានរៀបចំកម្មវិធីហ្វឹកហាត់បាល់ទាត់ Manchester United **Soccer School** ដែលជាវគ្គបណ្ដុះបណ្ដាល បាល់ទាល់លំដាប់ថ្នាក់អន្តរជាតិ មានការទទួលស្គាល់ក្នុងកំរិតសកលជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា។ នេះ បានសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ធនាគារ ក្នុងការចូលរួមចំណែកអភិវឌ្ឍយុវជន និងផ្តល់អត្ថប្រយោជន៍ពិសេសលើសពី សេវាកម្មធនាគារទៅកាន់អតិថិជន Premier របស់ខ្លួន។

កម្មវិធីហ្វឹកហាត់នេះ រៀបចំឡើងរយៈពេល បីថ្ងៃ ចាប់ពីថ្ងៃទី២៧រហូតដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥ នៅទីលានហ្វឹកហាត់ បឹងកេតហាយ-ធិច រាជធានីភ្នំពេញ ដោយបានផ្តល់ការហ្វឹកហាត់ដល់កុមារ និងយុវជនកម្ពុជាចំនួន១៦០នាក់ ក្រោមការបង្ហាត់បង្រៀន ពីក្រុមគ្រូបង្វឹកផ្លូវការ របស់ក្លឹបបាល់ទាត់ Manchester United ដែលជាក្លឹបល្បីល្បាញមួយរបស់ពិភពលោក។ ការរៀបចំកម្មវិធីនេះ បានឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់របស់ធនាគារ មេយប៊ែង  ទៅលើការចូលរួមយ៉ាងមានអត្ថន័យជាមួយអតិថិជន តាមរយៈបទពិសោធន៍ដែលលើសពីសេវាកម្មធនាគារទូទៅ។

**លោក រ័ត្ន សោភ័ណ** នាយកប្រតិបត្តិ និងនាយកប្រចាំប្រទេស របស់ធនាគារ មេយប៊ែង ខេមបូឌា បានបញ្ជាក់ថា៖ «កម្មវិធីនេះគឺមានន័យលើសពីកីឡាបាល់ទាត់ ដោយវាជាការកសាងទំនុកចិត្ត ការជម្រុញទស្សនៈវិស័យ និងជាឱកាសមួយក្នុងការផ្តល់បទពិសោធន៍លំដាប់ពិភពលោកដល់អតិថិជនរបស់យើង»។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងជាពិសេសជូនសម្រាប់អតិថិជន Maybank Premier និងអតិថិជនដែលជាម្ចាស់ប័ណ្ណឥណពន្ធវីសា Manchester United ដោយមានបំណងបង្ហាញនូវគុណតម្លៃ ដែលខុសប្លែករបស់សេវាកម្មធនាគារ តាមរយៈឱកាសដ៏កម្រផ្តល់ជូនទៅកាន់អតិថិជន។ អ្នកចូលរួម ទទួលបានវគ្គបណ្តុះបណ្តាល ដែលរៀបចំឡើងដោយផ្អែកលើទស្សនៈបាល់ទាត់ដ៏លេចធ្លោនៃក្លឹប Manchester United ដែលផ្តោតលើការអភិវឌ្ឍជំនាញបច្ចេកទេស សមត្ថភាពក្នុងការគិតយុទ្ធសាស្ត្រ និងការបណ្តុះវិន័យក្នុងការធ្វើការជាក្រុម។

បន្ថែមពីលើការបង្វឹកដែលមានជំនាញវិជ្ជាជីវៈពីក្រុមគ្រូបង្វឹក  រាល់អ្នកចូលរួមទាំងអស់ក៏ទទួលបានវិញ្ញាបនបត្រជាផ្លូវការនៃការចូលរួម  និងមេដាយពីកម្មវិធី **Manchester United Soccer School (MUSS)** ផងដែរ។ ហើយបទពិសោធន៍មួយដ៏មានតម្លៃនេះ នឹងប្រែក្លាយជាការចងចាំដោយមោទនភាព និងសមិទ្ធផលផ្ទាល់ខ្លួនសម្រាប់អ្នកចូលរួម។

**លោកស្រី ពុធ ធីតា** តំណាងដ៏ខ្ពង់ខ្ពស់មកពីសហភាពសហព័ន្ធយុវជនកម្ពុជា (សសយក) រាជធានីភ្នំពេញ បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស និងបានផ្តល់នូវការគាំទ្រចំពោះការចូលរួមរបស់យុវជនតាមរយៈកម្មវិធីនេះផងដែរ។ លោកស្រីបានគូសបញ្ជាក់ថា៖ «ការអភិវឌ្ឍយុវជនតែងតែជាចំណុចស្នូលសម្រាប់ការស្ថាបនាប្រទេសកម្ពុជាឲ្យរឹងមាំ និងរីកចម្រើន។ ខ្ញុំមានក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលបានឃើញស្ថាប័នដូចជា ធនាគារ មេយប៊ែង វិនិយោគលើកម្មវិធីដែលជម្រុញឲ្យយុវជនរបស់យើងបង្កើនក្តីសុបិនកាន់តែធំ និងមានគោលដៅកាន់តែខ្ពស់ តាមរយៈភាសាសកលនៃកីឡា»។

ជាផ្នែកមួយនៃការចូលរួមកាន់តែទូលំទូលាយ ក្រុមគ្រូបង្វឹករបស់ក្រុម Manchester United ក៏បានធ្វើវគ្គចែករំលែកនូវចំណេះដឹងយ៉ាងយកចិត្តទុកដាក់ជាមួយគ្រូបង្វឹកបាល់ទាត់កម្ពុជាផងដែរ។ វគ្គនេះផ្តោតលើគោលការណ៍បង្វឹក បច្ចេកទេសអភិវឌ្ឍន៍យុវជន និងវិធីសាស្ត្រជាក់ស្តែងក្នុងការបណ្តុះទេពកោសល្យដែលកំពុងរីកចម្រើន ដោយសំដៅលើការពង្រឹងសហគមន៍គ្រូបង្វឹកក្នុងស្រុក និងលើកកម្ពស់ការអភិវឌ្ឍបាល់ទាត់ប្រកបដោយចីរភាពនៅកម្ពុជា។

លោក **Michael Neary** ប្រធានគ្រូបង្វឹកនៃ **Manchester United Soccer School** បានអត្ថាធិប្បាយថា៖ «ទស្សនៈបង្វឹករបស់យើង គឺផ្តោតលើការអភិវឌ្ឍកីឡាករ និងគ្រូបង្វឹក ឲ្យក្លាយជាអ្នកដឹកនាំដែលមានសីលធម៌ មានបេសកកម្មច្បាស់លាស់ និងមានវិន័យខ្ពស់។ យើងមានមោទនភាពយ៉ាងខ្លាំងដែលបានធ្វើការជាមួយយុវជនដែលមានទេពកោសល្យនៅប្រទេសកម្ពុជា និងបានចំណាយពេលចែករំលែកគំនិត និងមតិយោបល់ជាមួយគ្រូបង្វឹកក្នុងស្រុកផងដែរ។ យើងខ្ញុំពិតជារំភើបខ្លាំងណាស់ ដែលឃើញក្រុមយុវជនប្រកបដោយសក្តានុពល និង ភាពក្លៀវក្លា នៅទីនេះ។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ធនាគារ មេយប៊ែង សម្រាប់ការចូលរួមសហការដែលមានន័យជាទីបំផុតនេះ និងសម្រាប់ការប្តេជ្ញាដ៏ខ្ពង់ខ្ពស់របស់ពួកគេចំពោះការរួមចំណែកអភិវឌ្ឍយុវជន និងសហគមន៍»។

ការរៀបចំជោគជ័យនៃកម្មវិធី **Manchester United Soccer School** នៅក្នុងប្រទេសកម្ពុជា ជាភស្តុតាងដ៏ជាក់ស្តែងនៃការប្តេជ្ញារយៈពេលវែងរបស់ធនាគារ មេយប៊ែង ចំពោះការអភិវឌ្ឍយុវជន ការបង្កើនសមត្ថភាពសហគមន៍ និងការបង្កើតនវានុវត្តន៍ផ្អែកលើតម្រូវការអតិថិជន ដែលជាកន្លែងផ្សំបញ្ចូលគ្នារវាង របៀបរស់នៅ ឱកាស និងគោលបំណង។

**ចុងក្រោយ លោក សុភ័ណ្ឌ បានបន្ថែមថា៖** «យើងមានមោទនភាពក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍយុវជនកម្ពុជា ខណៈពេលដែលផ្តល់ជូនអតិថិជនរបស់យើងនូវបទពិសោធន៍ ដែលពោលពេញទៅដោយអត្ថន័យ និងការជម្រុញទឹកចិត្ត។ នេះគឺជាផ្នែកមួយនៃចក្ខុវិស័យដ៏ទូលំទូលាយរបស់យើងក្នុងការផ្តល់នូវតម្លៃដែលមានសារៈសំខាន់ដល់អតិថិជនរបស់យើង»។

---

**អំពីធនាគារ មេយប៊ែង**

ធនាគារ មេយប៊ែង ជាសម្ព័ន្ធធនាគារដែលឈានមុខគេនៅអាស៊ី និងជាធនាគារធំជាងគេទីបួនរបស់អាស៊ីអាគ្នេយ៍បើគិតតាមទ្រព្យសកម្ម ។ ដោយមានវត្តមានក្នុង១៨ប្រទេស ធនាគារ មេយប៊ែង បានប្តេជ្ញាចិត្តក្នុងការផ្តល់នូវសេវាកម្មធនាគារប្រកបដោយអរិយភាពតាមរយៈគំនិតផ្តួចផ្តើម ភាពងាយស្រួល និងការយកចិត្តទុកដាក់ដល់សហគមន៍។ នៅប្រទេសកម្ពុជា ធនាគារ មេយប៊ែង នឹងបន្តជំរុញភាពជាអ្នកដឹកនាំរបស់ខ្លួនក្នុងការជួយដល់អតិថិជន ម្ចាស់សហគ្រាសធនតូច និងមធ្យម និងសេវាកម្មធនាគារ Premier Wealth ខណៈពេលដែលគាំទ្រយ៉ាងសកម្ម លើបរិវត្តកម្មឌីជីថល និងយុទ្ធនាការក្នុងការអភិវឌ្ឍន៍យុវជនផ្សេងៗ។

**អំពី Manchester United**

Manchester United គឺជាក្លឹបបាល់ទាត់ដ៏ល្បីល្បាញនិងមានប្រជាប្រិយភាពខ្ពស់មួយនៅលើពិភពលោក ដោយមានប្រវត្តិសាស្ត្រឈ្នះជាច្រើន មហាជនគាំទ្រយ៉ាងទូលំទូលាយនៅជុំវិញពិភពលោក និងការប្តេជ្ញាអភិវឌ្ឍទេពកោសល្យកីឡាករវ័យក្មេង។ ចាប់តាំងពីឆ្នាំ ១៨៧៨ មក ក្លឹបនេះបានជំរុញជំនាន់ក្រោយបន្តជាច្រើនតាមរយៈសមិទ្ធិផលកីឡា និងកម្មវិធីសហគមន៍នៅជុំវិញពិភពលោក។ កម្មវិធី Manchester United Soccer School គឺជាភស្តុតាងនៃមរតកដ៏អស្ចារ្យនេះ ដោយផ្តល់នូវការបណ្តុះបណ្តាលដល់កីឡាករវ័យក្មេងក្នុងលក្ខណៈវិជ្ជាជីវៈ តាមរយៈរចនាសម្ព័ន្ធបង្វឹកស្តង់ដារអន្តរជាតិ និងការអភិវឌ្ឍគ្រប់ទម្រង់។

***